**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ :...............០៧៣/១៤...........ក.ប/ស.ណ.ន

# សេចក្តីណែនាំ
# ស្តីពី
# នីតិវិធីនៃការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍

ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងឆ្លើយតបបានទាន់ពេលវេលានូវតម្រូវការរបស់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍ហើយពុំទាន់មានឯកសារគ្រប់គ្រាន់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃឡង់ដ៍នោះ **គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍** កំណត់នីតិវិធី និងយន្តការការងារនៃក្រុមការងារអន្តរក្រសួងចល័ត ដែលត្រូវប្រចាំនៅព្រះរាជាណាចក្រថៃឡង់ដ៍ដូចខាងក្រោម៖

## ក. តំណាងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវ៖

- សម្របសម្រួលជាមួយក្រសួងការងារថៃ ដើម្បីជូនដំណឹងដល់និយោជកថៃឱ្យជួយផ្សព្វផ្សាយដល់ពលករកម្ពុជា និងសម្របសម្រួលឱ្យពលករកម្ពុជាបានចេញមកបំពេញបែបបទនានាដើម្បីទទួលបានភាពស្របច្បាប់នៅទីកន្លែង និងមានចំនួនពលករសមស្របណាមួយតាមការព្រមព្រៀងរវាងអជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទាំងពីរ។
- រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីប្រចាំនៅក្នុងក្រុមការងារចល័តអន្តរក្រសួង អំពីនីតិវិធី វិន័យ និងក្រមសីលធម៌វិជ្ជាជីវៈក្នុងការផ្តល់សេវាដល់ពលករកម្ពុជា
- ផ្តល់ពាក្យសុំបម្រើការងារនៅព្រះរាជាណាចក្រថៃឡង់ដ៍ និងទម្រង់ប្រវត្តិរូបដល់ពលករកម្ពុជាជាមុនដល់និយោជក ឬនៅកន្លែងទីតាំងកំណត់ណាមួយដើម្បីប្រមូលគ្រប់គ្រងទិន្នន័យ និងអតីតភាពការងាររបស់ពលករទេសន្តរប្រវេសន៍កម្ពុជា
- ទទួលពិនិត្យសំណុំឯកសារបញ្ជីឈ្មោះពលករកម្ពុជា ដែលបានមកបំពេញពាក្យសុំធ្វើការដោយស្របច្បាប់នៅព្រះរាជាណាចក្រថៃឡង់ដ៍ឱ្យបានចប់នៅក្នុងថ្ងៃតែមួយ។ ឯកសារដែលត្រូវពិនិត្យរួមមាន៖
  - ពាក្យសុំចុះឈ្មោះជាពលករធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍ដោយស្របច្បាប់
  - ប្រវត្តិរូបរបស់ពលករកម្ពុជាដោយមានបិតរូបថតទំហំ ៤x៦ ចំនួន ១សន្លឹក
  - រូបថតទំហំ ៤x៦ របស់ពលករកម្ពុជាចំនួន ៣សន្លឹក
  - កិច្ចសន្យាការងារ រវាង ពលករកម្ពុជា ជាមួយ និយោជកថៃ
  - ប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស
- រៀបសំណុំឯកសារសម្រាប់ធ្វើលិខិតឆ្លងដែនធម្មតាជូនពលករ ដោយអាករជាបន្ទុករបស់រដ្ឋតាមស្មារតីប្រកាសរួមរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងមហាផ្ទៃ។

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ៤៨ ២៩

- ធ្វើរបាយការណ៍ប្រចាំសប្តាហ៍ជូន ប្រធានគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍ ដើម្បីសរុប និងរាយការណ៍បន្តជូនប្រមុខរាជរដ្ឋាភិបាល។

**ខ. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវ៖**

- សម្រួលនីតិវិធីការទូតជាមួយភាគីថៃ ដើម្បីបំពេញបេសកកម្មផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាតាមគោលការណ៍ជាធរមាន។

**គ. តំណាងក្រសួងមហាផ្ទៃ ត្រូវ៖**

- បំពេញបែបបទផ្តល់លិខិតឆ្លងដែនជូនពលករ ពលការិនីខ្មែរដែលត្រូវទៅធ្វើការស្របច្បាប់នៅបរទេសដោយអាករជាបន្ទុករបស់រដ្ឋ តាមសំណុំឯកសារស្នើសុំរបស់មន្ត្រីក្រុមការងារអន្តរក្រសួងចល័តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
- ផ្តល់លិខិតឆ្លងដែនធម្មតាជូនពលករ ពលការិនីខ្មែរដែលត្រូវទៅធ្វើការស្របច្បាប់នៅបរទេសក្នុងរយៈពេលយ៉ាងយូរ ១៥ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីពលករ ពលការិនីបានបំពេញបែបបទត្រឹមត្រូវនៅក្រុមការងារអន្តរក្រសួងចល័តរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ។
- បំពេញបែបបទផ្តល់លិខិតឆ្លងដែនដោយផ្ទាល់ដល់ពលករ ពលការិនី ដូចជា៖
  - បំពេញពាក្យសុំលិខិតឆ្លងដែន
  - ថតរូប
  - ផ្តិតខ្ទៅម្រាមដៃ
  - វាស់កម្ពស់
  - និងយកភិនភាគស្លាកស្នាម
- ពិនិត្យឯកសារដែលពលករត្រូវភ្ជាប់មកជាមួយ រួមមាន៖
  - សំបុត្រកំណើត ឬអត្តសញ្ញាណកម្មសញ្ជាតិខ្មែរ និង
  - សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ (ច្បាប់ដើម ឬច្បាប់ថតចម្លងដែលមានការបញ្ជាក់ថា បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)
- ប្រថាប់ត្រាចេញរបស់មន្ត្រីអន្តោប្រវេសន៍កម្ពុជា

ទទួលបានសារាចរនេះសូមឯកឧត្តម លោក លោកស្រី មន្ត្រីរាជការដែលទទួលបន្ទុកអនុវត្តភារកិច្ចខាងលើត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ "ដើម្បីជូនជ្រាប"
- ទីភ្នាក់ងារជ្រើសរើសឯកជន
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ